**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ:៣៩...អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការកែសម្រួលអនុក្រឹត្យលេខ៤៤ អនក្រ.បក ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧ ស្ដីពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ចរាចរណ៍ផ្លូវគោក

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើ ក្រមព្រហ្មទណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៥/០០១ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក៕

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៧/០០២ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៨ មាត្រា៤០ មាត្រា៤១ មាត្រា៤៧ មាត្រា៤៨ មាត្រា៧៥ មាត្រា៧៧ មាត្រា៨២ និងមាត្រា៩០ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២១៦អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីកែសម្រួលអនុក្រឹត្យលេខ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រាមួយ._**

មាត្រា៦ មាត្រា៧ មាត្រា៨ មាត្រា៩ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៣ មាត្រា១៤ និងមាត្រា១៥ នៃជំពូកទី៣ អំពើល្មើស និងចំនួនទឹកប្រាក់ត្រូវពិន័យអន្តរការណ៍ នៃអនុក្រឹត្យលេខ៤៤ អនក្រ.បក ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧ ស្តីពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ចរាចរណ៍ផ្លូវគោក ត្រូវបានកែសម្រួលដូចខាងក្រោម៖

### ជំពូកទី៣
### អំពើល្មើស និងចំនួនទឹកប្រាក់ត្រូវពិន័យអន្តរការណ៍

**មាត្រា៦ ថ្មី ._**

ត្រូវពិន័យអន្តរការណ៍ចំពោះអ្នកបើកបររទេះចក្រយានយន្ត ឬរទេះចក្រយានយន្តសណ្តោងរ៉ឺម៉ក ឬត្រីចក្រយានយន្ត ឬម៉ូតូកង់បួន ចំពោះអំពើល្មើសដូចខាងក្រោម៖

១.ត្រូវពិន័យទឹកប្រាក់ចំនួន ៦០ ០០០(ប្រាំមួយម៉ឺន) រៀល ចំពោះអ្នកបើកបរដែលបានប្រព្រឹត្តអំពើល្មើសដូចខាងក្រោម៖

ក-អ្នកបើកបរ និងអ្នករួមដំណើរ ព្រមទាំងកុមារដែលមានអាយុពី០៣(បី) ឆ្នាំឡើងទៅមិនពាក់មួកសុវត្ថិភាព ឬពាក់មួកសុវត្ថិភាពមិនត្រឹមត្រូវតាមស្តង់ដារជាតិ ឬពាក់មួកសុវត្ថិភាពដោយមិនដាក់គន្លឹះខ្សែសុវត្ថិភាព។ ការពិន័យអន្តរការណ៍ករណីល្មើសនេះ ត្រូវគិតតាមចំនួនជនប្រព្រឹត្តិល្មើស លើកលែងតែត្រីចក្រយានយន្ត ដែលមានដំបូលរឹងមាំបិទជិត។

ខ-បើកបររទេះចក្រយានយន្តមានទំហំស៊ីឡាំងលើសពី១២៥(មួយរយម្ភៃប្រាំ)សង់ទីម៉ែត្រគូប ឬមាន

ថាមពលអគ្គិសនីលើសពី១១(ដប់មួយ)គីឡូវ៉ាត់ ឬទោចក្រយានយន្តសណ្តោងរ៉ឺម៉ក ឬត្រីចក្រយានយន្ត ឬម៉ូតូកង់បួន ដែលមិនបានយកភ្ជាប់តាមខ្លួននូវឯកសារដើមនៃបណ្ណបើកបរយានយន្ត។

គ-ឈប់ ឬចតល្មើសនឹងមាត្រា២៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

ឃ-បើកបរដោយកុងទ័រល្បឿនមិនដំណើរការ។

ង-បើកបរលើសល្បឿនកំណត់ចាប់ពី១(មួយ)ទៅ១៩ (ដប់ប្រាំបួន)គីឡូម៉ែត្រក្នុងមួយម៉ោង។

ច-បើកបរដឹកអ្នកដំណើរលើសចំណុះល្មើសនឹងចំណុចទី៨ នៃមាត្រា៨ថ្មី នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក លើកលែងករណីដឹកអ្នកជម្ងឺ។

ឆ-បើកបរមិនគោរពសញ្ញាបញ្ជាចរាចរណ៍របស់មន្ត្រីនគរបាលចរាចរណ៍។

ជ-បើកបរដោយគ្មានកញ្ចក់មើលក្រោយ

**២. ត្រូវពិន័យទឹកប្រាក់ចំនួន ៨០ ០០០(ប្រាំបីម៉ឺន)រៀល ចំពោះអ្នកបើកបរដែលបានប្រព្រឹត្តអំពើល្មើសដូចខាងក្រោម៖**

ក-ប្រើទូរស័ព្ទនៅពេលបើកបរដោយគ្មានឧបករណ៍សម្លេងភ្ជាប់ទំនាក់ទំនង។

ខ-បើកបរប្រើសញ្ញាសូរសព្ទមិនត្រឹមត្រូវតាមប្បញ្ញត្តិច្បាប់។

គ-បើកបរដោយដាក់តាំងភ្លើង និងភ្លើងសញ្ញានៃយានមិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស។

ឃ-បើកបរលើសល្បឿនកំណត់ចាប់ពី២០(ម្ភៃ) ទៅ២៩ (ម្ភៃប្រាំបួន)គីឡូម៉ែត្រក្នុងមួយម៉ោង។

**៣.ត្រូវពិន័យទឹកប្រាក់ចំនួន ១០០ ០០០ (មួយសែន)រៀល ចំពោះអ្នកបើកបរដែលបានប្រព្រឹត្តអំពើល្មើស ដូចខាងក្រោម៖**

ក- បើកបរបង្ហោះ រេចុះរេឡើង ឆាបឬគៀរ។

ខ-បើកបរអូសជន្ទល់លើផ្លូវថ្នល់ ឬព្រលែងដៃចង្កូត ឬលើកជើងដាក់លើដៃចង្កូត។

គ-បើកបរបញ្ចេញសម្លេងម៉ាស៊ីនខ្លាំង ឬផ្សែងច្រើន ខុសពីបទដ្ឋានបច្ចេកទេស។

ឃ-បើកបរមិនគោរពលក្ខខណ្ឌសុខភាពតម្រូវឱ្យពាក់វ៉ែនតាដែលមានកំណត់ក្នុងបណ្ណបើកបរ។

ច- បើកបរខុសទិសចរាចរណ៍ ឬបើកបរជាន់គំនូសបង្ហូតកណ្តាលទ្រូងផ្លូវ។

ឆ-បើកបរលើសល្បឿនកំណត់ចាប់ពី៣០(សាមសិប) ទៅ ៣៩ (សាមសិបប្រាំបួន)គីឡូម៉ែត្រ ក្នុងមួយម៉ោង។

ជ- បើកបរល្មើសនឹងការជៀស ការបត់ និងការជែង។

ឈ-បើកបរល្មើសនឹងសិទ្ធិអាទិភាពផ្លូវប្រសព្វ។

ញ-ប្រើភ្លើងហ្វាកូត ឬភ្លើងសញ្ញាប្តូរទិសនៃយានមិនត្រឹមត្រូវ ឬកែច្នៃភ្លើងខុសបទដ្ឋានបច្ចេកទេស។

ដ-បើកបរដោយគ្មាន ឬមិនដំណើរការភ្លើងហ្វាកូត ភ្លើងបំភ្លឺផ្លាកលេខភ្លើងសញ្ញាប្តូរទិស ភ្លើងហ្វ្រាំង។

ឋ-បើកបរមិនគោរពភ្លើងសញ្ញាចរាចរណ៍ពណ៌ក្រហម ឬក្រហមភ្លឹបភ្លែតៗ។

ឌ-បើកបរមិនគោរពផ្លាកសញ្ញាហាមឃាត់ ឬផ្លាកសញ្ញាបញ្ជា ឬផ្លាកសញ្ញាសិទ្ធិអាទិភាពឬគំនូសសញ្ញាសម្រាប់ថ្មើរជើងឆ្លងកាត់។

ឍ-បើកបរផ្ទុកទំនិញល្មើសនឹងចំណុចទី១ ទី២ ទី៥ នៃមាត្រា៥៦ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

**៤ .ត្រូវពិន័យទឹកប្រាក់ចំនួន១២០ ០០០(មួយសែនពីរម៉ឺន)រៀល ចំពោះអ្នកបើកបរដែលបានប្រព្រឹត្តអំពើល្មើស ដូចខាងក្រោម៖**

ក-បើកបរដោយគ្មានបណ្ណបើកបរឬក្នុងរយៈពេលដែលបណ្ណបើកបរត្រូវបានដកហូត ព្យួរទុក ឬទុកជាមោឃៈ ឬហួសសុពលភាព។

ខ- បើកបរដោយគ្មានបណ្ណសម្គាល់ និង/ឬផ្លាកលេខ។

គ- បើកបរដោយមិនបានត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានតាមច្បាប់កំណត់។

ឃ- ប្តូរពណ៌យានយន្តដោយគ្មានការអនុញ្ញាត ឬបិទពណ៌មិនត្រឹមត្រូវតាមបណ្ណសម្គាល់យានយន្ត។

ង- ប្រើបណ្ណបើកបរមិនត្រឹមត្រូវតាមប្រភេទយាន។

ច- ប្រើផ្លាកលេខសម្គាល់យានដែលរចនាខុសពីលក្ខណៈដើម ឬលុបលេខ ឬបាក់ផ្លាក បាត់លេខ ឬដាក់សម្ភារៈ ឬវត្ថុផ្សេងៗបាំងផ្លាកលេខ។

៥. ត្រូវពិន័យទឹកប្រាក់ចំនួន ១៥០ ០០០(មួយសែនប្រាំម៉ឺន)រៀល ចំពោះអ្នកបើកបរដែលប្រណាំងគ្នាដោយគ្មានការអនុញ្ញាតលើផ្លូវសម្រាប់ធ្វើចរាចរណ៍ជាសាធារណៈ។

៦. ត្រូវពិន័យអន្តការណ៍ចំនួនទឹកប្រាក់ ២៥០ ០០០ (ពីរសែនប្រាំម៉ឺន)រៀល ចំពោះអ្នកបើកបរដែលស្ថិតក្នុងភាពស្រវឹងដែលមានអត្រាជាតិអាល់កុលចាប់ពី ០,២៥(សូន្យក្បៀសម្ភៃប្រាំ) ទៅ ០,៣៩(សូន្យក្បៀសសាមសិបប្រាំបួន)មីលីក្រាមក្នុងមួយលីត្រខ្យល់ ឬចាប់ពី ០,៥(សូន្យក្បៀសប្រាំ) ទៅ ០,៧៩(សូន្យក្បៀសចិតសិបប្រាំបួន)ក្រាមក្នុងមួយលីត្រឈាម។

ក្នុងករណីនេះ ត្រូវបញ្ឈប់មិនឱ្យបើកបរបន្តដំណើរទៅមុខទៀត។

**មាត្រា៧ ថ្មី.-**

ត្រូវពិន័យអន្តរការណ៍ចំពោះអ្នកបើកបរយានយន្តធុនស្រាល និងអ្នកបើកបរយានយន្តធុនធ្ងន់ដែលប្រព្រឹត្តអំពើល្មើសដូចខាងក្រោម៖

១. ត្រូវពិន័យអ្នកបើកបរយានយន្តធុនស្រាលទឹកប្រាក់ចំនួន ៧៥ ០០០(ប្រាំពីរម៉ឺនប្រាំពាន់)រៀល និងអ្នកបើកបរយានយន្តធុនធ្ងន់ទឹកប្រាក់ចំនួន ១៥០ ០០០(មួយសែនប្រាំម៉ឺន)រៀល ចំពោះអំពើល្មើសដូចខាងក្រោម៖

ក- បើកបរមិនបានយកភ្ជាប់តាមខ្លួននូវឯកសារដើមរួមមាន បណ្ណបើកបរយានយន្ត និងលិខិតអនុញ្ញាតធ្វើអាជីវកម្មចំពោះរថយន្តដែលប្រកបអាជីវកម្មដឹកជញ្ជូន។

ខ- បើកបរដោយមិនពាក់ខ្សែក្រវ៉ាត់សុវត្ថិភាព។

គ- ឈប់ ឬចតល្មើសនឹងមាត្រា២៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

ឃ- បើកបរដោយកុងទ័រល្បឿនមិនដំណើរការ។

ច- បើកបរដឹកអ្នកដំណើរលើសចំណុះល្មើសនឹងចំណុចទី៨ មាត្រា៨ថ្មី និងចំណុចទី៦ នៃមាត្រា៦៦ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

ឆ- អ្នកបើកបរយានយន្តធុនធ្ងន់យានយន្តបករណ៍យានយន្តសណ្តោងរ៉ឺម៉ុក ឬសីមីរ៉ឺម៉ុកបិទស្លាកសញ្ញាចាំងពន្លឺខុសបទដ្ឋានកំណត់ ឬមិនមានបិទស្លាកសញ្ញាចាំងពន្លឺ។

២. ត្រូវពិន័យអ្នកបើកបរយានយន្តធុនស្រាលទឹកប្រាក់ចំនួន ១២០ ០០០(មួយសែនពីរម៉ឺន)រៀល និងអ្នកបើកបរយានយន្តធុនធ្ងន់ទឹកប្រាក់ចំនួន ២២៥ ០០០(ពីរសែនពីរម៉ឺនប្រាំពាន់)រៀល ចំពោះអំពើល្មើសដូចខាងក្រោម៖

ក- បើកបរប្រើទូរស័ព្ទគ្មានឧបករណ៍សម្លេងភ្ជាប់ទំនាក់ទំនង។

ខ- បើកបរប្រើសញ្ញាសូរស័ព្ទមិនត្រឹមត្រូវតាមប្បញ្ញត្តិច្បាប់។

គ- បើកបរដោយដាក់តាំងភ្លើង និងភ្លើងសញ្ញានៃយាន មិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស។

ឃ- បើកបរដោយគ្មានឆ្លិតទឹកជូតកញ្ចក់មុខ ឬឆ្លិតទឹកជូតកញ្ចក់មុខមិនដំណើរការ ឬកញ្ចក់មុខ ឬកញ្ចក់ក្រោយមានប្រេះស្រាំដែលលំបាកមើលផ្លូវ ឬគ្មានកញ្ចក់មើលក្រោយ។

ង-បើកបរមានប៊ូឡុងកង់ ឬអេគ្រូកង់មិនគ្រប់តាមចំនួនកំណត់នៃប្រភេទរថយន្តនីមួយៗ។

ច-បើកបរលើសល្បឿនកំណត់ចាប់ពី១ (មួយ) ទៅ១៩(ដប់ប្រាំបួន)គីឡូម៉ែត្រក្នុងមួយម៉ោង។

ឆ-បើកបររថយន្តធ្វើអាជីវកម្មផ្ទាល់ខ្លួនដឹកអ្នកដំណើរ ឬដឹកទំនិញ គ្មានសញ្ញាសម្គាល់បញ្ជាក់អំពីទំហំទម្ងន់រថយន្ត ទម្ងន់ផ្ទុក ចំណុះផ្ទុក ចំនួនភ្លៅ ឬប្រើសញ្ញាសម្គាល់មិនត្រឹមត្រូវ។

ជ-បើកបរល្មើសនឹងបែបបទនៃការសណ្តោងយានដូចមានចែងក្នុងមាត្រា១៤ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

ឈ-បើកបរដោយមិនបានប្រើភ្លើងសញ្ញាអាសន្ន ឬមិនបានដាក់សញ្ញាត្រីកោណជាដំណឹង ក្នុងករណីដែលយានយន្តខូចមិនអាចរំកិលចេញពីទ្រូងផ្លូវបាន។

ញ-បើកបររថយន្តដឹកទំនិញមានគ្រោះថ្នាក់គ្មានសញ្ញាសម្គាល់ ឬប្រើសញ្ញាសម្គាល់មិនត្រឹមត្រូវ។

៣. ត្រូវពិន័យអ្នកបើកបរយានយន្តធុនស្រាលទឹកប្រាក់ចំនួន ១៥០ ០០០(មួយសែនប្រាំម៉ឺន)រៀល និងអ្នកបើកបរយានយន្តធុនធ្ងន់ទឹកប្រាក់ចំនួន៣០០ ០០០(បីសែន)រៀល ចំពោះអំពើល្មើសដូចខាងក្រោម៖

ក- បើកបរបង្ហោះ រេចុះរេឡើង ឆាបឬគៀរ។

ខ- បើកបរបញ្ចេញសម្លេងម៉ាស៊ីនខ្លាំង ឬផ្សែងច្រើន ខុសពីបទដ្ឋានបច្ចេកទេស។

គ-បើកបរយានយន្តផ្ទាល់ខ្លួនដោយគ្មានលិខិតអនុញ្ញាតធ្វើអាជីវកម្ម ឬប្រើលិខិតធ្វើអាជីវកម្មហួសសុពលភាព។

ឃ- បើកបរមិនគោរពលក្ខខណ្ឌសុខភាព ដែលតម្រូវឱ្យពាក់វ៉ែនតា។

ច- បើកបរខុសទិសចរាចរណ៍ ឬបើកបរជាន់គំនូសបង្គូតកណ្តាលទ្រូងផ្លូវ។

ឆ-បើកបរលើសល្បឿនកំណត់ចាប់ពី២០(ម្ភៃ) ទៅ២៩ (ម្ភៃប្រាំបួន) គីឡូម៉ែត្រក្នុងមួយម៉ោង។

ជ-បើកបរល្មើសនឹងការជៀស ការបត់ និងការជែង។

ឈ- បើកបរល្មើសនឹងសិទ្ធិអាទិភាពផ្លូវប្រសព្វ។

ញ-ប្រើភ្លើងហ្វាកូតឬភ្លើងសញ្ញាប្តូរទិសនៃយានមិនត្រឹមត្រូវ ឬកែច្នៃភ្លើងខុសបទដ្ឋានបច្ចេកទេស។

ដ-បើកបរដោយគ្មាន ឬមិនដំណើរការភ្លើងហ្វាកូត ភ្លើងសញ្ញាប្តូរទិស ភ្លើងហ្វ្រាំង ភ្លើងទីតាំងខាងមុខរថយន្ត និងភ្លើងក្រហមខាងក្រោយរថយន្ត។

ឋ- បើកបរមិនគោរពភ្លើងសញ្ញាចរាចរណ៍ពណ៌ក្រហម ឬក្រហមភ្លឹបភ្លែតៗ។

ឌ-បើកបរមិនគោរពផ្លាកសញ្ញាហាមឃាត់ ឬផ្លាកសញ្ញាបញ្ជា ឬផ្លាកសញ្ញាសិទ្ធិអាទិភាព ឬគំនូសសញ្ញាសម្រាប់ថ្មើរជើងឆ្លងកាត់។

ឍ-បើកបរប្រើប្រាស់សំបកកង់សឹកលើសកម្រិតកំណត់ ឬរហែក ឬប្រេះ ឬប៉ោង។

ណ-បើកបរមិនគោរពសញ្ញាបញ្ជាចរាចរណ៍របស់មន្ត្រីនគរបាលចរាចរណ៍។

ត-បើកបរផ្ទុកទំនិញល្មើសនឹងចំណុចទី១ ទី២ ទី៣ ទី៤ ទី៥ មាត្រា៥៦ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវ គោក។

ថ-បើកបររថយន្តធុនធ្ងន់ដែលគ្មានរនាំងសុវត្ថិភាព ឬមានរនាំងសុវត្ថិភាពមិនត្រឹមត្រូវតាមតួរថយន្តខាងក្រោម ឬគ្មានគន្លឹះសុវត្ថិភាពសម្រាប់ភ្ជាប់កុងតែន័រ ឬមានគន្លឹះសុវត្ថិភាពសម្រាប់ភ្ជាប់កុងតែន័រមិនគ្រប់

គ្រាន់ ឬគន្លឹះសុវត្ថិភាពសម្រាប់ភ្ជាប់កុងតែន័រមិនដំណើរការ។

៤.ត្រូវពិន័យអ្នកបើកបរយានយន្តធុនស្រាលទឹកប្រាក់ចំនួន ១៨០ ០០០(មួយសែនប្រាំបីម៉ឺន)រៀល និងអ្នកបើកបរយានយន្តធុនធ្ងន់ទឹកប្រាក់ចំនួន៣៧៥ ០០០ (បីសែនប្រាំពីរម៉ឺនប្រាំពាន់)រៀល ចំពោះអំពើល្មើសដូចខាងក្រោម៖

ក-បើកបរដោយគ្មានវិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយាន ឬប្រើវិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសហួសសុពលភាព។

ខ- ប្តូរពណ៌យានយន្តដោយគ្មានការអនុញ្ញាត ឬបិទពណ៌មិនត្រឹមត្រូវតាមបណ្ណសម្គាល់យានយន្ត។

គ-ប្រើប្រាស់បណ្ណបើកបរមិនត្រឹមត្រូវតាមប្រភេទយាន។

ឃ- ប្រើបណ្ណបើកបរយានយន្តហួសសុពលភាព។

ង- បើកបរយានយន្តែលមានកង់ច្រវ៉ាក់ដែកផ្ទាល់នៅលើទ្រូងផ្លូវថ្នល់ក្រាលកៅស៊ូ។

ច- ប្រើប្រាស់ផ្លាកលេខសម្គាល់យានដែលរចនាខុសពីលក្ខណៈដើម ឬលុបលេខ ឬបាក់ផ្លាក បាត់លេខ ឬដាក់សម្ភារៈឬវត្ថុផ្សេងៗបាំង ផ្លាកលេខ។

ឆ-បើកបរលើសល្បឿនកំណត់ចាប់ពី៣០ (សាមសិប) ទៅ ៣៩ (សាមសិបប្រាំបួន)គីឡូម៉ែត្រក្នុងម៉ោង។

៥.ត្រូវពិន័យអ្នកបើកបរយានយន្តធុនស្រាលទឹកប្រាក់ចំនួន ៣០០ ០០០ (សាមសិបម៉ឺន)រៀល និងអ្នកបើកបរយានយន្តធុនធ្ងន់ទឹកប្រាក់ចំនួន៦២៥ ០០០(ប្រាំមួយសែនពីរម៉ឺនប្រាំពាន់)រៀល ចំពោះអំពើល្មើសដូចខាងក្រោម៖

ក- បើកបរយានយន្តដែលកែច្នៃដំឡើងខុសបទដ្ឋានបច្ចេកទេស។

ខ-បើកបរប្រណាំងគ្នាដោយគ្មានការអនុញ្ញាតលើផ្លូវសម្រាប់ធ្វើចរាចរណ៍ជាសាធារណៈ។

គ. បើកបរលើសល្បឿនកំណត់ចាប់ពី៤០ (សែសិប)គីឡូម៉ែត្រ ក្នុងមួយម៉ោងឡើងទៅ។

៦.ត្រូវពិន័យអន្តរការណ៍ចំពោះអ្នកបើកបរស្ថិតក្នុងភាពស្រវឹងដែលមានអត្រាជាតិអាល់កុលចាប់ពី ០,២៥ (សូន្យក្បៀសម្ភៃប្រាំ) ទៅ ០,៣៩ (សូន្យក្បៀសសាមសិបប្រាំបួន)មីលីក្រាម ក្នុងមួយលីត្រខ្យល់ ឬ ចាប់ពី ០,៥ (សូន្យក្បៀសប្រាំ) ទៅ ០,៧៩ (សូន្យក្បៀស ចិតសិបប្រាំបួន) ក្រាមក្នុងមួយលីត្រឈាមដូចតទៅ៖

-ទឹកប្រាក់ចំនួន៤០០ ០០០ (បួនសែន)រៀល សម្រាប់យានយន្តធុនស្រាល

-ទឹកប្រាក់ចំនួន៨០០ ០០០(ប្រាំបីសែន) រៀលសម្រាប់យានយន្តធុនធ្ងន់។

ក្នុងករណីនេះ ត្រូវបញ្ឈប់មិនឱ្យបន្តដំណើរទៅមុខទៀត។

**មាត្រា៨ ថ្មី.**

ត្រូវពិន័យអន្តរការណ៍ចំពោះអ្នកបើកបរយានយន្តដោយគ្មានបណ្ណបើកបរ ឬក្នុងរយៈពេលដែលបណ្ណបើកបរត្រូវបានដកហូត ព្យួរទុក ឬទុកជាមោឃៈ ដូចតទៅ៖

-ទឹកប្រាក់ចំនួន ១ ២០០ ០០០ (មួយលានពីរសែន)រៀល សម្រាប់យានយន្តធុនស្រាល

-ទឹកប្រាក់ចំនួន ២ ៤០០ ០០០(ពីរលានបួនសែន)រៀល សម្រាប់យានយន្តធុនធ្ងន់។

ក្នុងករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍ម្តងរួចហើយ តែនៅបន្តប្រព្រឹត្តបទល្មើសនេះទៀតក្នុងរយៈពេល៦(ប្រាំមួយ)ខែ ចាប់គិតពីការពិន័យអន្តរការណ៍លើកមុន ត្រូវផ្តន្ទាទោសតាមច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។ ក្នុងករណីនេះមន្ត្រីនគរបាលចរាចរណ៍ផ្លូវគោក ត្រូវរៀបចំកំណត់ហេតុបញ្ជូន

ទៅអយ្យការអមសាលាដំបូង ដើម្បីចាត់វិធានការតាមច្បាប់ជាធរមាន។

**មាត្រា៩ ថ្មី._**

ត្រូវពិន័យអន្តរការណ៍ចំពោះអ្នកបើកបរយានយន្តដោយគ្មានបណ្ណសម្គាល់យានជំនិះ និង/ឬគ្មានផ្លាកលេខ ដូចតទៅ៖

-ទឹកប្រាក់ចំនួន ១ ២០០ ០០០ (មួយលានពីរសែន)រៀល សម្រាប់យានយន្តធុនស្រាល

-ទឹកប្រាក់ចំនួន ២ ៤០០ ០០០(ពីរលានបួនសែន)រៀល សម្រាប់យានយន្តធុនធ្ងន់។

ក្នុងករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍ម្តងរួចហើយ តែនៅបន្តប្រព្រឹត្តបទល្មើសនេះទៀតក្នុងរយៈពេល ៦(ប្រាំមួយ)ខែ ចាប់គិតពីការពិន័យអន្តរការណ៍លើកមុន ត្រូវផ្តន្ទាទោសតាមច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។ ក្នុងករណីនេះ មន្ត្រីនគរបាលចរាចរណ៍ផ្លូវគោកត្រូវរៀបចំកំណត់ហេតុបញ្ជូនទៅអយ្យការអមសាលាដំបូង ដើម្បីចាត់វិធានការតាមច្បាប់ជាធរមាន។

**មាត្រា១០ថ្មី._**

ត្រូវពិន័យអន្តរការណ៍ចំពោះអ្នកបើកបរយានយន្តស្ថិតក្នុងភាពស្រវឹង ដែលមានអត្រាជាតិអាល់កុលចាប់ពី០,៤០ (សូន្យក្បៀសសែសិប)មីលីក្រាម ក្នុងមួយលីត្រខ្យល់ ឬចាប់ពី០,៨០ (សូន្យក្បៀសប៉ែតសិប)ក្រាមក្នុងមួយលីត្រឈាមឡើងទៅ ដូចតទៅ៖

-ទឹកប្រាក់ចំនួន ១ ០០០ ០០០(មួយលាន) សម្រាប់ រៀលទោចក្រយានយន្ត ឬទោចក្រយានយន្តសណ្តោងរ៉ឺម៉ុក ឬត្រីចក្រយានយន្ត ឬម៉ូតូកង់បួន

-ទឹកប្រាក់ចំនួន ២ ០០០ ០០០ (ពីរលាន)រៀល សម្រាប់យានយន្តធុនស្រាល

-ទឹកប្រាក់ចំនួន ៤ ០០០ ០០០(បួនលាន) រៀលសម្រាប់យានយន្តធុនធ្ងន់។

ក្នុងករណីនេះ ត្រូវបញ្ឈប់មិនឱ្យបន្តដំណើរទៅមុខទៀត។

ក្នុងករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍ម្តងរួចហើយ តែនៅបន្តប្រព្រឹត្តបទល្មើសនេះទៀតក្នុងរយៈពេល ៦(ប្រាំមួយ)ខែ ចាប់គិតពីការពិន័យអន្តរការណ៍លើកមុន ត្រូវផ្តន្ទាទោសតាមច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។ ក្នុងករណីនេះ មន្ត្រីនគរបាលចរាចរណ៍ផ្លូវគោកត្រូវរៀបចំកំណត់ហេតុបញ្ជូនទៅអយ្យការអមសាលាដំបូង ដើម្បីចាត់វិធានការតាមច្បាប់ជាធរមាន។

**មាត្រា១១ថ្មី._**

ម្ចាស់ហាងលក់យានយន្តគ្រប់ប្រភេទដែលមិនបានបំពេញបែបបទចុះបញ្ជីយានយន្តសុំបណ្ណសម្គាល់យានយន្ត និងសុំផ្លាកលេខសម្គាល់យានយន្តឱ្យបានចប់សព្វគ្រប់មុនប្រគល់ឱ្យអ្នកទិញ ត្រូវទទួលរងពិន័យអន្តរការណ៍ដូចតទៅ៖

-ទឹកប្រាក់ចំនួន១២០ ០០០(មួយសែនពីរម៉ឺន)រៀលសម្រាប់ទោចក្រយានយន្ត ឬទោចក្រយានយន្តសណ្តោងរ៉ឺម៉ុក ឬត្រីចក្រយានយន្ត ឬម៉ូតូកង់បួន

-ទឹកប្រាក់ចំនួន ១ ២០០ ០០០ (មួយលានពីរសែន)រៀល សម្រាប់យានយន្តធុនស្រាល

-ទឹកប្រាក់ចំនួន ២ ៤០០ ០០០(ពីរលានបួនសែន)រៀល សម្រាប់យានយន្តធុនធ្ងន់។

ត្រូវពិន័យអន្តរការណ៍ចំពោះនីតិបុគ្គលដែលមិនបានស្នើសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូន ដូច

តទៅ៖

-ទឹកប្រាក់ចំនួន ១៥០ ០០០ (មួយសែនប្រាំម៉ឺន)រៀល សម្រាប់យានយន្តធុនស្រាល

-ទឹកប្រាក់ចំនួន ៣០០ ០០០(បីសែន)រៀល សម្រាប់យានយន្តធុនធ្ងន់។

**មាត្រា១២ថ្មី.-**

ជនណាដែលស្ថិតក្រោមឥទ្ធិពលនៃគ្រឿងញៀន មិនអនុញ្ញាតឱ្យបើកបរយានយន្តឡើយ។ អ្នកបើកបរយានយន្តស្ថិតក្រោមឥទ្ធិពលនៃគ្រឿងញៀន ត្រូវផ្តន្ទាទោសតាមច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**មាត្រា១៣ថ្មី.-**

ឪពុកម្តាយឬអាណាព្យាបាលត្រូវបង់ប្រាក់ពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងអនុក្រឹត្យនេះ ដែលប្រព្រឹត្តដោយអនីតិជនមានអាយុចាប់ពី១៥(ដប់ប្រាំ)ឆ្នាំ ដល់ក្រោម ១៨(ដប់ប្រាំបី)ឆ្នាំ។

**មាត្រា១៤ថ្មី.-**

ជនដែលបានប្រព្រឹត្តល្មើសនឹងមាត្រាមួយមាត្រា៦ថ្មីមាត្រា៧ថ្មីមាត្រា៨ថ្មីមាត្រា៩ថ្មី និងមាត្រា១០ ថ្មី ត្រូវបង់ប្រាក់ពិន័យអន្តរការណ៍ក្នុងរយៈពេល ១៥(ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការគិតពីថ្ងៃដែលបានទទួលបង្កាន់ដៃបង់ប្រាក់ពិន័យអន្តរការណ៍។

ក្នុងករណីមិនបានបង់ប្រាក់ពិន័យអន្តរការណ៍លើសរយៈពេល១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ គិតពីថ្ងៃដែលបានទទួលបង្កាន់ដៃបង់ប្រាក់ពិន័យអន្តរការណ៍ចំនួនទឹកប្រាក់ពិន័យនេះត្រូវដំឡើងជាពីរដង។

ក្នុងករណីមិនបានបង់ប្រាក់ពិន័យអន្តរការណ៍លើសរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ ចំនួនទឹកប្រាក់ពិន័យនេះត្រូវដំឡើងជាបីដង។

ក្នុងករណីមិនបានបង់ប្រាក់ពិន័យអន្តរការណ៍លើសរយៈពេល៦០(ហុកសិប)ថ្ងៃនៃថ្ងៃធ្វើការ មន្ត្រីមានសមត្ថកិច្ចត្រូវរៀបចំកំណត់ហេតុបញ្ជូនទៅអយ្យការអមសាលាដំបូង ដើម្បីចាត់វិធានការតាមច្បាប់ជាធរមាន។

ទម្រង់បែបបទនៃបង្កាន់ដៃពិន័យនិងការគ្រប់គ្រងប្រាក់ចំណូលដែលបានមកពីការពិន័យអន្តរការណ៍ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា១៥ថ្មី.-**

បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់មន្ត្រីមានសមត្ថកិច្ចដូចមានចែងក្នុងមាត្រា៤ នៃអនុក្រឹត្យលេខ៤៤ អនក្រ.បក ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧ ស្តីពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក មានសិទ្ធិប្តឹងតវ៉ារយៈពេល ១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការយ៉ាងយូរ គិតពីថ្ងៃទទួលបង្កាន់ដៃពិន័យអន្តរការណ៍ទៅប្រធានអង្គភាពដែលគ្រប់គ្រងលើមន្ត្រីអនុវត្តផ្ទាល់ គឺ៖

-នៅថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវប្តឹងតវ៉ាទៅអធិការនគរបាលក្រុង ស្រុក ខណ្ឌ

-នៅថ្នាក់រាជធានីខេត្ត ត្រូវប្តឹងតវ៉ាទៅស្នងការនគរបាលរាជធានីខេត្ត

-នៅថ្នាក់ក្រសួង ត្រូវប្តឹងតវ៉ាទៅប្រធាននាយកដ្ឋាននគរបាលចរាចរណ៍និង សណ្តាប់ធ្នាប់សាធារណៈ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ។ ប្រធានអង្គភាពត្រូវសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការយ៉ាងយូរ គិតពីថ្ងៃទទួលបណ្តឹង។

បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ប្រធានអង្គភាពខាងលើ មានសិទ្ធិប្តឹងទៅតុលាការតាម

នីតិវិធីច្បាប់។

**មាត្រា៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ...អង្គារ...៩...រោច...ខែ...ផល្គុន...ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី...១៧...ខែ...មីនា......ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

នៃព្រះរាជាណាចក្រកម្ពុជា សូមហត្ថលេខា។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

កន្លែងទទួលៈ

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា៤
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ